# នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខៈ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារៈ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូនៈ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើមៈ អង់គ្លេស និងភាសាខ្មែរ

កាលបរិច្ឆេទឯកសារៈ ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៦

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 02-May-2016, 14:42
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារៈ សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ **សម្ងាត់/Confidential**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្នៈ

ឈ្មោះមន្ត្រីកត់ត្រាៈ

ហត្ថលេខាៈ

---

## ចម្លើយតបរបស់សហមេធាវីនាំមុខ នៅនឹងសំណើរបស់ នួន ជា អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង សុំប្រើប្រាស់ចម្លើយសារភាព ស២១ មួយចំនួន

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គឹមសួន

គឹម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

សំ សុគង់

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

ចៅក្រម Claudia FENZ

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

វ៉ែន ពៅ

ទី ស្រ៊ីនណា

Laure DESFORGES
Ferdinand DJAMMEN NZEPA
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI

**<u>ជនជាប់ចោទ៖</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីការពារក្តី៖</u>**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ

**<u>មេធាវីប្រចាំការ៖</u>**

ទូច វរល័ក្ស

Calvin SAUNDERS

**<u>សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

Olivier BAHOUGNE
Patrick BAUDOUIN
Beini Ye

*ចម្លើយតបរបស់សហមេធាវីនាំមុខ ទៅនឹងសំណើរបស់នួន ជា អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង សុំប្រើប្រាស់ ចម្លើយសារភាព ស២១ មួយចំនួន*

Original EN: 01226885-01226893

## I. សេចក្ដីផ្ដើម

1. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") សូមឆ្លើយតបទៅនឹង *សំណើរបស់ នួន ជា អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង សុំប្រើប្រាស់ចម្លើយសារភាព សឝ២១ មួយចំនួន* ("សំណើ") ដែលលើកឡើងថា ចម្លើយសារភាព និងឯកសារដែលទាក់ទងនឹងបុគ្គល ៣ នាក់ ដែលត្រូវបានឃុំឃាំងនៅ ស២១ គ្មានហានិភ័យពិតប្រាកដដែលថា ចម្លើយទាំងនោះបានមកពីការធ្វើទារុណកម្មទេ[1]។

## II. ច្បាប់ជាធរមាន

2. មាត្រាទី១៥ នៃអនុសញ្ញាស្ដីពីការប្រឆាំងទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ចែងថា "ឯកសាររាយការណ៍ទាំងឡាយ ដែលបង្កើតឡើងបានមកពីអំពើទារុណកម្ម មិនត្រូវយកមកសំអាងជាធាតុនៃភស្ដុតាងក្នុងនីតិវិធីណាមួយ លើកលែងតែឯកសាររាយការណ៍នោះ ត្រូវបានធ្វើសម្រាប់ជាភស្ដុតាងប្រឆាំងនឹងជនជាប់ចោទនៃអំពើទារុណកម្ម"[2]។

3. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា វិធានបដិសេធភ័ស្ដុតាង អនុវត្តបានចំពោះភាគីទាំងអស់ក្នុងករណីនេះ "រួមទាំងមេធាវីការពារក្ដីរបស់ នួន ជា ផងដែរ និងភ័ស្ដុតាងដែលបានមកពីការធ្វើទារុណកម្មដែលមេធាវីការពារក្ដីអះអាងថាជាភ័ស្ដុតាងដោះបន្ទុក"[3]។ ទាំងអង្គជំនុំជម្រះតុលាការ

[1] សំណើរបស់នួន ជា អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង សុំប្រើប្រាស់ចម្លើយសារភាព ស២១ មួយចំនួន , E399, ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៦ ("សំណើ")។

[2] អនុសញ្ញាស្ដីពីការប្រឆាំងទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨៤។

[3] សេចក្ដីសម្រេចលើភស្ដុតាងដែលបានដោយការធ្វើទារុណកម្ម, E350/8, ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦, កថាខណ្ឌ ៤៧។

កំពូល និងអង្គជំនុំជម្រះសាលាដំបូង ផ្តល់លទ្ធភាពតិចតួចក្នុងការប្រើប្រាស់ភស្តុតាងនោះ ប្រសិនបើការបដិសេធនោះ បណ្តាលឲ្យមាន "យុត្តិនិសេធជាក់ស្តែង"[4]។

4. នីតិវិធីដែលត្រូវអនុវត្តទាក់ទងនឹងភស្តុតាងដែលអាចទទួលបានមកពីការធ្វើទារុណកម្ម ត្រូវបានពន្យល់ដោយអង្គជំនុំជម្រះសាលាដំបូង។ ចម្លើយសារភាពមួយ *ត្រូវបានពិនិត្យឃើញថា* ទទួលបានតាមរយៈការធ្វើទារុណកម្ម ដូចមានចែងក្នុងវិធាន១៥ ដែលមានហានិភ័យពិតប្រាកដ ដែលថាចម្លើយទាំងនោះ បានមកពីការធ្វើទារុណកម្ម[5]។ បន្ទាប់ពីមានការសម្រេចជាបឋមថា មានហានិភ័យពិតប្រាកដមែនដែលថា អំពើទារុណកម្មត្រូវបានប្រើប្រាស់ ដើម្បីទទួលបានចម្លើយសារភាពនោះ "ភាគីណាដែលស្នើការប្រើប្រាស់ភស្តុតាងនោះ អាចជំទាស់ទៅនឹងការសម្រេចជាបឋមនេះ ជាពិសេស បន្ទាប់ពីបង្ហាញពីកាលៈទេសៈជាក់លាក់ផ្សេងៗ ដែលបដិសេធហានិភ័យនេះ"[6]។

5. អង្គជំនុំជម្រះសាលាដំបូងបានធ្វើសេចក្តីសម្រេចជាបឋមរួចហើយថា មានហានិភ័យពិតប្រាកដដែលថា ការធ្វើទារុណកម្មត្រូវបានធ្វើឡើងនៅ ស២១ ដើម្បីទទួលចម្លើយសារភាព ហើយអង្គជំនុំជម្រះនឹងមិនអនុញ្ញាតឲ្យប្រើប្រាស់ចម្លើយសារភាពទាំងនោះឡើយ "លើកលែងតែភាគីដែលស្នើសុំឲ្យប្រើភស្តុតាង បង្ហាញឲ្យឃើញថា មិនមានហានិភ័យពិតប្រាកដ ដែលថា ភស្តុតាងនោះបានមកតាមរយៈការធ្វើទារុណកម្ម ឬក៏ថាវាស្ថិតនៅក្នុងអញ្ញត្រកម្មនៃមាត្រា១៥"[7]។

6. ជាចុងក្រោយ "បន្ទាប់ពីធ្វើការវាយតម្លៃទៅលើគ្រប់កាលៈទេសៈដែលពាក់ព័ន្ធទាំងអស់ អង្គជំនុំជម្រះនឹងកំណត់ថាតើមានហានិភ័យពិតប្រាកដដែលថា ភស្តុតាងនោះ បានទទួលតាមរយៈការធ្វើ

[4] សេចក្តីសម្រេចលើភស្តុតាងដែលបានដោយការធ្វើទារុណកម្ម, E350/8, ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦, កថាខណ្ឌ ៤៨, សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ, F26/12, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥, កថាខណ្ឌ ៦៤-៦៥។

[5] សេចក្តីសម្រេចលើភស្តុតាងដែលបានដោយការធ្វើទារុណកម្ម, E350/8, ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦, កថាខណ្ឌ ៣៦, សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ, F26/12, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥, កថាខណ្ឌ ៥៥។

[6] សេចក្តីសម្រេចលើភស្តុតាងដែលបានដោយការធ្វើទារុណកម្ម, E350/8, កថាខណ្ឌ ៣៦។

[7] សេចក្តីសម្រេចលើភស្តុតាងដែលបានដោយការធ្វើទារុណកម្ម, E350/8, កថាខណ្ឌ ៣៧, ៣៨។

ទារុណកម្មដែរឬទេ”[8]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា បទដ្ឋាននៃការបង្ហាញភ័ស្តុតាងថា មានហានិភ័យពិតប្រាកដ មានកម្រិតទាបជាងបទដ្ឋានដែលត្រូវបានអនុវត្តចំពោះសេចក្ដីសម្រេចចុងក្រោយរបស់ខ្លួនថាតើការធ្វើទារុណកម្មបានកើតឡើងដែរឬទេនោះ[9]។ ជាលទ្ធផល ការវាយតម្លៃបែបនោះធ្វើឱ្យមានការបដិសេធភ័ស្តុតាង[10]។

7. វិធាន ៩៣ (១) នៃវិធានផ្ទៃក្នុង ចែងថា “ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការស៊ើបសួរថ្មីជាការចាំបាច់ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឱ្យធ្វើការស៊ើបអង្កេតបន្ថែមបានគ្រប់ពេលវេលា។ សាលក្រមមុនអង្គសេចក្ដីនេះត្រូវកំណត់បង្ហាញអំពីចៅក្រមមួយរូប ឬច្រើនរូបដែលត្រូវជាអ្នកដឹកនាំការស៊ើបសួរថ្មីនេះ”[11]។ អនុលោមតាមវិធាននេះ អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិផ្ដួចផ្ដើមឱ្យមានកិច្ចស៊ើបសួរថ្មី ដែលអាចរួមមានការស្ដាប់ចម្លើយសាក្សី ឬដឹកនាំការឆែកឆេរ នៅពេលដែលចាំបាច់។ ភាពចាំបាច់នេះត្រូវតែសម្អាងទៅលើផលប្រយោជន៍នៃយុត្តិធម៌[12]។ កន្លងមក អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ឆន្ទានុសិទ្ធរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវតែពិនិត្យមើល “នៅក្នុងបរិបទនៃក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ដែលធានានូវសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស ហើយប្រធានសវនាការមានឆន្ទានុសិទ្ធិក្នុងការបដិសេធនូវរាល់នីតិវិធីដែលនាំឱ្យមានការពន្យារដល់ការជំនុំជម្រះ”[13]។

## IV. ចម្លើយតប

---

[8] សេចក្ដីសម្រេចលើភស្តុតាងដែលបានដោយការធ្វើទារុណកម្ម, E350/8, កថាខណ្ឌ ៣៨។

[9] សេចក្ដីសម្រេចលើភស្តុតាងដែលបានដោយការធ្វើទារុណកម្ម, E350/8, កថាខណ្ឌ ៣៩។

[10] សេចក្ដីសម្រេចលើភស្តុតាងដែលបានដោយការធ្វើទារុណកម្ម, E350/8, កថាខណ្ឌ ៣៩។

[11] *សូមមើលផងដែរ* មាត្រា ៣៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលអនុញ្ញាតឱ្យតុលាការសាលាដំបូង បង្គាប់ឱ្យធ្វើការស៊ើបអង្កេតបន្ថែម ក្នុងអំឡុងពេលជំនុំជម្រះក្ដី។

[12] សេចក្ដីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឱ្យទទួលយកភ័ស្តុតាងថ្មី ឱ្យចាប់ផ្ដើមការស៊ើបអង្កេត និងឱ្យកោះហៅលោក ROB LEMKIN, E294/1, ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣, កថាខណ្ឌ ១១។

[13] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ១១ *ដកស្រង់*ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះក្នុងតុលាការកម្ពុជា, មាត្រា៣៣ ថ្មី, វិធានផ្ទៃក្នុង៨៥។

*ចម្លើយតបរបស់សហមេធាវីនាំមុខ ទៅនឹងសំណើរបស់នួន ជា អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង សុំប្រើប្រាស់ ចម្លើយសារភាព ស២១ មួយចំនួន*

Original EN: 01226885-01226893

8. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសន្និដ្ឋានថា មិនមានភាពចម្រូងចម្រាស់ទេដែលថា ចម្លើយសារភាពដែលត្រូវស្នើឱ្យក្រុមមេធាវីការពារប្រើប្រាស់នោះ ទទួលបានពី ស២១ ហើយចម្លើយសារភាពទាំងនោះត្រូវបានពិនិត្យឃើញថាមានហានិភ័យខ្ពស់ដែលថា ចម្លើយទាំងនោះទទួលបានមកតាមរយៈការធ្វើទារុណកម្ម។ ដូច្នេះ ក្រុមមេធាវីការពារក្ដីមានកាតព្វកិច្ចក្នុងការបង្ហាញពីកាលៈទេសៈជាក់លាក់ផ្សេងៗ ដែលអាចបដិសេធហានិភ័យនេះ។

9. អង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់ "ភ្លាមៗ" ថា មានហានិភ័យពិតប្រាកដដែលថាចម្លើយសារភាពនៅស២១ ទទួលបានពីការធ្វើទារុណកម្ម។ អង្គជំនុំជម្រះតុលាការកំពូលបានផ្អែកទៅលើសេចក្ដីសន្និដ្ឋានរបស់ខ្លួន និងសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ ជាពិសេសលើការសន្និដ្ឋានថា វិធីសាស្ត្រធ្វើទារុណកម្ម "ត្រូវបានអនុវត្តក្នុងស្ថានភាពដែលពោរពេញទៅដោយការភ័យខ្លាចយ៉ាងខ្លាំង ដែលការគំរាមកំហែងទាំងនេះ ត្រូវបានប្រើប្រាស់ជាប្រចាំ និងធ្វើឱ្យអ្នកជាប់ឃុំឃាំងមានការឈឺចាប់ធ្ងន់ធ្ងរលើរាងកាយ និងផ្លូវចិត្ត[14], "បុគ្គលិកទាំងនោះបានប្រព្រឹត្តអំពើដែលជាបទល្មើសនៃការធ្វើទារុណកម្ម ក្នុងគោលបំណងដើម្បីទទួលបានចម្លើយសារភាព ឬក្នុងគោលបំណងដាក់ទណ្ឌកម្ម"[15], អ្នកជាប់ឃុំឃាំងនៅ ស២១ ទទួលរងការសួរចម្លើយជាប្រព័ន្ធដោយមានការប្រើអំពើហិង្សាជាប្រចាំ[16] អ្នកជាប់ឃុំឃាំងនៅនៅមន្ទីរស២១ "រស់នៅក្នុងបរិយាកាសខ្លាចជាអចិន្ត្រៃយ៍"[17] ហើយអ្នកជាប់ឃុំឃាំងនៅមន្ទីរ ស២១ "អាចស្ដាប់ឮសំឡេងស្រែក និងអាចឃើញថា អ្នកជាប់ឃុំឃាំងដទៃទៀត ពេលត្រឡប់មកពីការសួរចម្លើយវិញ មានស្នាមវាយធ្ងន់ធ្ងរ ស្នាមដាច់រយៈ ស្នាមជាំ និងស្នាមមុត"[18]។

10. អង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើសំអាងហេតុរបស់ខ្លួននៅក្នុងសំណុំរឿង០០១ ក្នុងការធ្វើសេចក្ដីសន្និដ្ឋានថា មាន "ហានិភ័យពិតប្រាកដដែលថាចម្លើយសារភាពនៅ ស២១ ទទួលបានមកពី

---

[14] សេចក្ដីសម្រេចលើសេចក្ដីជំទាស់ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ, F26/12, កថាខណ្ឌ៥៦ (ដកស្រង់សាលដីកាលើបណ្ដឹងសាទុក្ខ ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២, កថាខណ្ឌ ២០៨)។

[15] សេចក្ដីសម្រេចលើសេចក្ដីជំទាស់ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ, F26/12, កថាខណ្ឌ៥៦ (ដកស្រង់សាលដីកាលើបណ្ដឹងសារទុក្ខ ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២, កថាខណ្ឌ ២០៨)។

[16] សេចក្ដីសម្រេចលើសេចក្ដីជំទាស់ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ, F26/12, កថាខណ្ឌ៥៧។

[17] សេចក្ដីសម្រេចលើសេចក្ដីជំទាស់ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ, F26/12, កថាខណ្ឌ៥៧។

[18] សេចក្ដីសម្រេចលើសេចក្ដីជំទាស់ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ, F26/12, កថាខណ្ឌ៥៧។

ការធ្វើទារុណកម្ម"[19] ជាពិសេស "ថា អំពើទារុណកម្មត្រូវបានប្រើប្រាស់ដើម្បីបានចម្លើយសារភាពនៅមន្ទីរ ស២១ ថា នៅពេលដែលអ្នកជាប់ឃុំមិនបានឆ្លើយឲ្យពេញចិត្តអ្នកសួរចម្លើយទេនោះ អំពើទារុណកម្មបន្ថែមត្រូវបានអនុវត្ត ហើយថា ភាគច្រើននៃព័ត៌មានដែលមាននៅក្នុងចម្លើយសារភាពទាំងនោះ ត្រូវបានប្រឌិតឡើង"[20]។

11. សហមេធាវីនាំមុខយល់ឃើញថា កាលៈទេសៈទាំងនេះពុំត្រូវបានជំទាស់ដោយសេចក្ដីសន្និដ្ឋាននានានៅក្នុងសំណើ ដោយផ្អែកទៅលើចំណុចខាងក្រោម។

### *(ក) សំណើនេះពុំបានបង្ហាញថា ពុំមានហានិភ័យពិតប្រាកដដែលថា ចម្លើយសារភាពរបស់ កុយ ធួន នៅ ស២១ ទទួលបានតាមរយៈការធ្វើទារុណកម្មឡើយ*

12. សំណើនេះលើកឡើងថា "មានភស្តុតាងដែលគួរឲ្យជឿជាក់បានដែលបង្ហាញថា នៅក្នុងករណី កុយ ធួន ចម្លើយសារភាពនៅ ស២១ របស់គាត់ មិនត្រូវបានធ្វើឡើងដោយទារុណកម្មឡើយ"[21] ដោយសំអាងលើការសារភាពរបស់ ឌុច ដែលថាបានសួរចម្លើយ កុយ ធួន ដោយផ្ទាល់, ការបដិសេធរបស់ ឌុច ថាមិនបានប្រើប្រាស់ការធ្វើទារុណកម្មក្នុងអំឡុងពេលសួរចម្លើយ និងសេចក្ដីសម្រេចនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ ដែលថា ឌុច ពុំបានទទួលខុសត្រូវចំពោះ "ការធ្វើទារុណកម្ម ឬអំពើអមនុស្សធម៌ដទៃទៀត តាមរយៈការប្រព្រឹត្តិដោយរូបកាយ ឬតាមអំពើអកម្មដែលមានពិរុទ្ធភាពឡើយ"[22]។

13. ទីមួយ សហមេធាវីនាំមុខលើកឡើងថា អង្គហេតុដែលពុំមានការជំទាស់ដែលថា ចម្លើយសារភាពទទួលបានពី ស២១ នៅក្នុងកាលៈទេសៈ ដែលទាំងអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល បានពិពណ៌នានៅក្នុងការសម្រេចថា ចម្លើយសារភាពនៅ ស២១ ត្រូវបានពិនិត្យ

---

[19] សេចក្ដីសម្រេចលើភស្តុតាងដែលបានដោយការធ្វើទារុណកម្ម, E350/8, កថាខណ្ឌ ៧៩។

[20] សេចក្ដីសម្រេចលើភស្តុតាងដែលបានដោយការធ្វើទារុណកម្ម, E350/8, កថាខណ្ឌ ៧៩។

[21] សំណើ,E399, កថាខណ្ឌ ១៨។

[22] សំណើ,E399, កថាខណ្ឌ ១៦-១៧។

ឃើញថាទទួលបានពីការធ្វើទារុណកម្ម បង្ហាញថា មានហានិភ័យពិតប្រាកដដែលថាចម្លើយសារភាពនោះ បានមកពីការធ្វើទារុណកម្ម[23]។

14. ទីពីរ ឌុច ត្រូវបានកាត់ឱ្យជាប់ទោសចំពោះការប្រព្រឹត្តិនានាជាមួយសមាជិកសហឧក្រិដ្ឋកម្មរួមដទៃទៀត និងតាមរយៈអ្នកក្រោមបង្គាប់របស់គាត់ "ដើម្បីប្រតិបត្តិការមន្ទីរ ស២១ ដែលត្រូវចាត់ទុកថាជាកន្លែងឃុំខ្លួន សួរចម្លើយ និងសម្លាប់ដោយខុសច្បាប់ ចំពោះជនទាំងឡាយណាដែលគេយល់ថាជាសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា ទាំងជនជាតិខ្មែរ និងជនបរទេស។ ប្រព័ន្ធសហការរួមនៃការធ្វើបាប និងការធ្វើទារុណកម្ម ត្រូវបានអនុវត្តដោយចេតនា ដើម្បីបង្ក្រាបអ្នកជាប់ឃុំ និងទាញយកចម្លើយសារភាពពីអ្នកជាប់ឃុំក្នុងពេលសួរចម្លើយ"[24]។ ដូច្នេះ ចម្លើយរបស់គាត់ ដែលថា ការធ្វើទារុណកម្មពុំត្រូវបានប្រើប្រាស់ ពុំអាចលើកឡើងនូវកាលៈទេសៈ ដើម្បីបដិសេធហានិភ័យពិតប្រាកដដែលថា ការធ្វើទារុណកម្មត្រូវបានប្រើប្រាស់ដើម្បីទទួលបានចម្លើយសារភាពរបស់កុយ ធឿន នៅស២១ ឡើយ។ លើសពីនេះទៀត ការប្រើពាក្យ "ទារុណកម្ម" របស់ឌុច ពុំអាចសន្និដ្ឋានថាជាការប្រើប្រាស់និយមន័យច្បាប់សម្រាប់ពាក្យទារុណកម្មនោះទេ ហើយដូច្នេះ វាក៏ពុំអាចបដិសេធហានិភ័យពិតប្រាកដដែលថា ចម្លើយសារភាពបាន មកពីការធ្វើទារុណកម្មនោះដែរ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ថាកថាខណ្ឌមួយចំនួននៃសាលក្រមសំណុំរឿង ០០១ ដែលត្រូវបានដកស្រង់ដោយក្រុមមេធាវីការពារក្តី លើកឡើងអំពី ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលរបស់ ឌុច ចំពោះការធ្វើទារុណកម្ម ឬអំពើអមនុស្សធម៌ដទៃទៀត តាមរយៈការប្រព្រឹត្តិដោយរូបកាយ ឬតាមអំពើអកម្មដែលមានពិរុទ្ធភាព[25]។ សេចក្តីសម្រេចទាំងនេះមិនមែនជាការសម្រេចថាតើ កុយ ធួន ទទួលរងទារុណកម្មក្នុងអំឡុងពេលឃុំឃាំងនៅ ស២១ ឬក៏ថាតើចម្លើយរបស់គាត់ទទួលបានពីការធ្វើទារុណកម្មដែរឬយ៉ាងណាឡើយ។

15. ទីបី សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ថា នៅលើគែមទំព័រនៃចម្លើយសារភាពរបស់ កុយ ធួន មានចំណារមួយដែលសរសេរថា គាត់បានឆ្លើយ ឬសារភាព នៅពេល

---

[23] *ដូចឯកសារយោងខាងលើ,* កថាខណ្ឌ ៩-១០។

[24] សាលក្រមសំណុំរឿង០០១, E188, កថាខណ្ឌ ៥១៤។

[25] សំណើ,E399, កថាខណ្ឌ ១៧ (ដកស្រង់សាលក្រមសំណុំរឿង០០១, E188, កថាខណ្ឌ ៤៨៣-៤៨៦)។

ដែល *គាត់ត្រូវបានចោះម្ខាង* [26]។ ចំណារផ្សេងៗទៀតផ្តល់នូវមន្ទិលសង្ស័យពីភាពដែលអាចជឿទុកចិត្តបាននៃអត្ថន័យរបស់ចម្លើយសារភាពរបស់ កុយ ធួន ដោយមានចំនុចខុសៗគ្នាជាច្រើនដែលយោងទៅនឹងចម្លើយសារភាពនោះ ថាមិនជាក់លាក់ ឬប្រឌិត[27]។

### *(ខ) សំណើនេះ ពុំបានបង្ហាញថា ពុំមានហានិភ័យពិតប្រាកដដែលថាចម្លើយសារភាពរបស់ យឹម សម្បត្តិ ទទួលបានតាមរយៈការធ្វើទារុណកម្មឡើយ*

16. ពុំមានភាពចម្រូងចម្រាស់ទេដែលថា ចម្លើយសារភាពរបស់ យឹម សម្បត្តិ ទទួលបាននៅស២១នោះ។ នៅកថាខណ្ឌ ២០ និង២១ ក្រុមមេធាវីការពារក្តីអះអាងថា ដោយសារតែកំណត់ហេតុសួរចម្លើយ ឌុច ទាំងពីររបស់ ក.ស.ច.ស ថ្លែងថា មានបញ្ជាពី សុន សេន កុំឲ្យធ្វើទារុណកម្មលើ យឹម សម្បត្តិ ហើយ ហ៊ី បានសួរចម្លើយដោយពុំមានការធ្វើទារុណកម្មនោះ មាន "ភស្តុតាងបញ្ជាក់ច្បាស់" ថា ចម្លើយសារភាពរបស់គាត់នៅ ស២១ មិនទទួលបានពីការធ្វើទារុណកម្មទេ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា អង្គហេតុដែលមិនមានការជំទាស់ដែលថា ចម្លើយសារភាពរបស់គាត់ត្រូវបានធ្វើឡើងនៅ ស២១ នោះ បង្ហាញថាមានហានិភ័យពិតប្រាកដដែលថាចម្លើយសារភាពទទួលបានមកពីការធ្វើទារុណកម្ម ដោយផ្អែកលើស្ថានភាពចាប់បង្ខំនៅ ២១ ដូចដែលអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងខាងលើ[28]។

17. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា សក្ខីកម្មរបស់ ឌុច ដែលផ្តល់ឲ្យ ក.ស.ច.ស ដែលថា យឹម សម្បត្តិ មិនត្រូវបានធ្វើទារុណកម្ម ពុំអាចបដិសេធហានិយភ័យពិតប្រាកដដែល ថា ចម្លើយសារភាពរបស់គាត់ នៅ ស២១ ទទួលបានមកពីការធ្វើទារុណកម្ម ផ្អែក

---

[26] E3/1604 ERN 00006159 (ភាសាខ្មែរ)។

[27] *សូមមើលជាឧទាហរណ៍*, ឯកសារ **E3/1604** ERN 00773088, 00773089, 00773113, 00773115 (ភាសាអង់គ្លេស)។ ចំណារផ្សេងៗទៀតដែលបញ្ជាក់ថាចម្លើយសារភាពរបស់ កុយ ធួន បានផ្លាស់ប្តូរជានិច្ច។ *សូមមើល* ឯកសារ **E3/1604** ERN00773116, 00773119, 00773121(ភាសាអង់គ្លេស)។

[28] *ដូចឯកសារយោងខាងលើ*, កថាខណ្ឌ ៩-១០។

ទៅលើមូលហេតុដូចគ្នាទៅនឹងករណីចម្លើយសារភាពរបស់កុយ ធួន នៅ ស២១ ក៏ទទួលបានមកពីការធ្វើទារុណកម្មផងដែរ[29]។

18. សំខាន់ជាងនេះទៅទៀត នៅក្នុងសំណុំរឿង ០០២/០១ ឌុច បានផ្តល់សក្ខីកម្មថា "ដោយឡែក យឹម សម្បត្តិ គឺជាអ្នកបោកគ្រាប់បែក ហើយបន្ទាប់មក គាត់ក៏ត្រូវបានគេចាប់ខ្លួន និងឃុំនៅ ស២១។ មេហាមមិនឲ្យវ៉ៃមែន ប៉ុន្តែមិនឲ្យខ្ញុំសួរ មិនឲ្យ មិត្តប៉ុន សួរទេ គឺឲ្យអ្នកផ្សេងទៀតសួរ ខ្ញុំឲ្យ មិត្ត ហ៊ី សួរ។ ក៏ប៉ុន្តែដល់ក្រោយមក វ៉ៃ មានវ៉ៃ"[30]។

19. លើសពីនេះទៀត យឹម វ៉ាក ហៅ ហ៊ី ដែលជាអនុរបស់ ឌុច បានធ្វើការសួរចម្លើយ ពុំមែន ឌុច ខ្លួនឯងផ្ទាល់ទេ[31]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ថា ហ៊ី គឺជាសមាជិកសហឧក្រិដ្ឋកម្មរួមម្នាក់ ជាមួយ ឌុច ហើយ "បានទទួលភារកិច្ចគ្រប់គ្រងដំណើរការប្រចាំថ្ងៃរបស់មន្ទីរ ស២១ និងត្រួតពិនិត្យមើលការងាររបស់កងការពារ និងអ្នកសួរចម្លើយនៅមន្ទីរ ស២១"[32]។ ហ៊ី ដោយមានការឯកភាពពី ឌុច "អាចចាត់ចែងការសម្លាប់អ្នកជាប់ឃុំនៅមន្ទីរស២១ ដោយមានជំនួយពីអ្នកនៅក្រោមបង្គាប់"[33]។

***(គ) សំណើនេះ ពុំបានបង្ហាញថា ពុំមានហានិភ័យពិតប្រាកដដែលថា ចម្លើយសារភាពរបស់ ជា ធន់ ហៅ សួង ទទួលបានតាមរយៈការធ្វើទារុណកម្មឡើយ***

[29] *ដូចខាងក្រោម*, កថាខណ្ឌ ១៤។

[30] ប្រតិចារឹក សំណុំរឿង ០០២/០១ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២, ឯកសារ **E1/54.1**, ទំព័រ១០, បន្ទាត់ ១៥-១៩ ERN 00795577(ភាសាអង់គ្លេស), ERN ០០៧៩៤០៣០(ភាសាខ្មែរ)។

[31] សំណើ,E399, កថាខណ្ឌ ២០ (ដកស្រង់ E3/356 ERN 00096949, E319/42.3.1 ERN 01213411)។

[32] សាលក្រមសំណុំរឿង០០១, E188, កថាខណ្ឌ ១៣៣ (*សូមមើលផងដែរ* កថាខណ្ឌ ៥១៤)។

[33] សាលក្រមសំណុំរឿង០០១, E188, កថាខណ្ឌ ១៨១ ។

20. ក្រុមមេធាវីការពារក្តីស្នើឲ្យពិចារណាឡើងវិញទៅលើសេចក្តីសម្រេចកន្លងមករបស់អង្គជំនុំជម្រះ ដែលបានសម្រេចថា ចម្លើយសារភាពរបស់ ជា នន់ នៅ ស ២១ អាចត្រូវបានសន្និដ្ឋានថាទទួលបានពីការធ្វើទារុណកម្ម[34]។

21. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ថា សំណើនេះមិនត្រូវបានដាក់ទាន់ពេលវេលាឡើយ។ ក្រុមមេធាវីការពារក្តីបានស្នើសុំប្រើប្រាស់ចម្លើយសារភាពនៅ ស២១ របស់ ជា ណុន នៅក្នុងសវនាការ កាលពីថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ នៅពេលមានការលើកឡើងអំពីបញ្ហានៃការមិនមានចំណារនៅក្នុងសំណៅជាភាសាខ្មែរ[35]។ មិនមានភាពច្បាស់លាស់ថាហេតុអ្វីបានជាជិតមួយឆ្នាំក្រោយមកមក ទើបក្រុមមេធាវីការពាក្តីស្នើសុំប្រើប្រាស់ចំណារនៅក្នុងសំណៅជាភាសាខ្មែរ ដែលមាននៅដើមឯកសារនោះ ធ្វើជាកាលៈទេសៈថ្មី ដែលតម្រូវឲ្យធ្វើការពិចារណាឡើងវិញ។

22. ជាបឋម សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា ទោះបីជាមានចំណារដែលបង្ហាញថា ចម្លើយសារភាពត្រូវធ្វើឡើងដោយពុំមានការបង្ខំក៏ដោយ ក៏ចម្លើយសារភាពទាំងនោះនៅតែបានទទួលនៅ ស២១ ក្រោមស្ថានភាព ដែលទាំងអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលពិពណ៌នាថា ចម្លើយសារភាពទាំងនោះមានហានិភ័យពិតប្រាកដថាទទួលបានមកពីការធ្វើទារុណកម្ម[36]។ ហានិភ័យនេះពុំអាចត្រូវបានបដិសេធដោយការមានចំណារនោះឡើយ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ថា ឯកសារទាំងមូលហាក់ដូចជាស៊ីសង្វាក់គ្នាទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងកថាខណ្ឌ ១៧៦ ថា មានការណែនាំឲ្យសួរចម្លើយអ្នកទោសឡើងវិញរហូតដល់ការសារភាពបានចប់សព្វគ្រប់[37]។

23. នៅក្នុងកថាខណ្ឌ ៣០ ក្រុមមេធាវីការពារក្តីស្នើថា “ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងមិនជឿជាក់លើប្រភព ឬយថាភាពនៃចំណារទាំងនេះ” គួរបង្គាប់ឲ្យមានការស៊ើបអង្កេតបន្ថែម

---

[34] សំណើ,E399, កថាខណ្ឌ ២៥,២៩ E350/8, កថាខណ្ឌ ៨៦។

[35] សំណើ,E399, កថាខណ្ឌ ២៣-២៤។

[36] *ដូចខាងលើ*, កថខាណ្ឌ ០៩-១០។

[37] សាលក្រមសំណុំរឿង០០១, E188, កថាខណ្ឌ ១៧៦។

អនុលោមតាមវិធាន ៩៣។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ថា ឯកសារនេះទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយហាក់ដូចជាឯកសារថតចម្លង។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីរម្លឹកអំពីយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះ ដែលថា ប្រភពឯកសារបែបនេះ "រារាំងមិនអាចឲ្យធ្វើការប្រៀបធៀបអក្សរសរសេរដោយដៃពិតប្រាកដបានឡើយ និងបង្កើតនូវឧបសគ្គយ៉ាងខ្លាំងដល់ការវិភាគតាមបែបកោសល្យវិច័យឲ្យបានត្រឹមត្រូវ ដែលកាលៈទេសនេះ អាចត្រូវបានចាត់ទុកថា មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុ ដែលជាគោលដៅនៃការស្នើសុំពិនិត្យភ័ស្តុតាង"[38]។

## V. សំណើ

24. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើដោយក្តីគោរពដល់អង្គជំនុំជម្រះសាលាដំបូងឲ្យ៖

(១) **ច្រានចោល**សំណើនេះ។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៦ | ពេជ អង្គ<br>សហមេធាវីនាំមុខ<br><br>Marie GUIRAUD<br>សហមេធាវីនាំមុខ | ភ្នំពេញ | |

[38] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឲ្យ មានការវាយតម្លៃដោយអ្នកជំនាញលើឯកសារ E3/2107, E349/1 ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥, កថាខណ្ឌ ៥។

*ចម្លើយតបរបស់សហមេធាវីនាំមុខ ទៅនឹងសំណើរបស់ខ្លួន ជា អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង សុំប្រើប្រាស់ ចម្លើយសារភាព ស២១ មួយចំនួន*

Original EN: 01226885-01226893